ឯកឧត្តម ចម ប្រសិទ្ធ ជួបពិភាក្សាលើកទី១ ជាមួយប្រតិភូមកពីសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា







នៅរសៀលថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានអនុញ្ញាតឱ្យប្រតិភូសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ដឹកនាំដោយ ឯកឧត្តម **សុន គន្ធរ** ប្រធានសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ដើម្បីសម្តែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួង ។





មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងបានចាត់ទុកថា ជាការជួបគ្នាលើកដំបូងរវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលជាអាណាព្យាបាល ជាមួយសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា តាំងពីសភានេះបានកកើតឡើងតាំងពីឆ្នាំ២០០៥ ស្ថិតក្រោមការគ្រប់គ្រងដំបូង របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបន្តថាៈសហគ្រាសខ្នាតតូច និងមធ្យម នៅកម្ពុជា មានជាង ៥សែន ទីតាំង ក្នុងនោះផ្នែកមីក្រូសហគ្រាស គឺមានចំនួនច្រើនលើសលប់ ។ ដូច្នេះការបង្កើតសភាមុខរបរ និងមីក្រូសហគ្រាសនេះ គឺមានសារៈសំខាន់ណាស់ ដើម្បីជួយមីក្រូសហគ្រាស ឱ្យមានការវិវឌ្ឍន៍រីកចម្រើន ក្នុងដំណាក់កាលនៃសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន នឹងលេចចេញជារូបរៀងនាពេលឆាប់ៗខាងមុខនេះ ។

ឯកឧត្តម **សុន គន្ធរ** ប្រធានសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា បានសម្តែងទឹកចិត្តរីករាយចំពោះជំនួបថ្ងៃនេះ ហើយនឹងបានសុំអនុសាសន៍ណែនាំពីឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ផងដែរ ។ ឯកឧត្តម **សុន គន្ធរ** បានជម្រាបថា: សភាមុខរបរ និងមីក្រូសហគ្រាស គឺជាអង្គភាពឯកជន ចងក្រងឡើងនៅឆ្នាំ២០០៥ ហើយនៅឆ្នាំ ២០០៦ បានធ្វើការជ្រើសរើសក្រុម ប្រឹក្សាភិបាលចំនួន៦៤ នាក់ និងមានក្រុមប្រឹក្សាប្រតិបត្តិចំនួន១៤នាក់ ។ ដំណាក់កាលដំបូងមានការជួយឧបត្ថម្ភពីប្រទេសអាល្លឺម៉ង់ និងក្រោយមកគឺបានការឧបត្ថម្ភថវិកាស្ម័គ្រចិត្តពីសមាជិករបស់ខ្លួន ។ បច្ចុប្បន្នសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជាបានបង្កើតតាមបណ្តាខេត្តក្រុងមួយចំនួន ដូចជា រាជធានីភ្នំពេញ–សៀមរាប–បាត់ដំបង–ស្វាយរៀង–កំពង់ចាម ហើយកំពុងស្ថាបស្ថ៍តាមបណ្តាខេត្តមួយចំនួនទៀត ។ សភាមុខរបរ បានធ្វើសកម្មភាពមួយចំនួន រួមមាន : ធ្វើសិក្ខាសាលា–ទស្សនៈកិច្ចសិក្សានៅក្រៅប្រទេស –និងធ្វើកសិដ្ឋានដាំបន្លែសាកល្បង ជាដើម ។ ទន្ទឹមនិងនេះ សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ក៏មានការជួបផលវិបាកផងដែរ ដូចជា: ផ្នែកធន់ធានថវិកា និងធនធានមនុស្ស ជាដើម។

ជាការផ្តល់មតិ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានណែនាំឱ្យសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ផ្តោតការយកចិត្តទុកដាក់ ទៅលើការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញគ្រប់គ្រង ដើម្បីឱ្យពួកគេមានលទ្ធភាព ពង្រីកមុខរបរ មានការគ្រប់គ្រងកាន់តែប្រសើរ ហើយពង្រីកខ្លួនទៅ ជាសហគ្រាសខ្នាតមធ្យមបាន ។ ប៉ុន្តែអ្វីដែលជាការចាប់ផ្តើមដ៏សំខាន់នោះ គឺត្រូវធ្វើយ៉ាងណាប្រមូលផ្តុំប្រភេទមីក្រូសហគ្រាសទាំងអស់ តាមរយៈការគៀងគរឱ្យមកចុះបញ្ជីនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពីព្រោះការមកចុះបញ្ជី នឹងទទួលបានផលប្រយោជន៍ជាច្រើន ដូចជា :ទទួលបានភាពស្របច្បាប់ –ងាយស្រួលគ្រប់គ្រង–មានលទ្ធភាពជួយឧបត្ថម្ភ និងការបណ្តុះបណ្តាល ក៏ដូចជាការចែករំលែកព័ត៌មាន ។ល។

ឆ្លៀតឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានអំពាវនាវឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងរៀបចំ ឯកសារគតិយុត្ត ដើម្បីគៀងគរឱ្យខ្នាតមីក្រូសហគ្រាសបានមកចុះបញ្ជី នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម រាជធានី–ខេត្ត ឱ្យបានច្រើនជាអតិបរិមា និងសូមបញ្ជាក់ថា: ក្រសួងមិនយកកម្រៃសេវាចុះបញ្ជីឡើយ ។

